# សេចក្ដីសង្ឃឹមតាមរយៈព្រះយេស៊ូវគ្រីស្ទ

## ហេតុអ្វីខ្ញុំត្រូវការជំនួយរបស់ព្រះយេស៊ូវគ្រីស្ទដើម្បីបានល្អឥតខ្ចោះ ?

អែលឌើរ ជេ ដេវណ៍ ខូនីស្ស នៃពួកចិតសិបនាក់បានចែកចាយ ៖



សមាជិកយើងសួរខ្លួនឯងជាញឹកញាប់ថា « តើខ្ញុំជាមនុស្សគ្រប់លក្ខណ៍ហើយឬនៅ ? » ឬ « តើខ្ញុំពិតជាអាចទៅកាន់នគរសេឡេស្ទាលបានដែរឬទេ ? » ប្រាកដណាស់ គ្មាននរណាម្នាក់ « បានគ្រប់លក្ខណ៍ » នោះទេ ។ ខ្ញុំសូមបកស្រាយចម្ងល់នេះថា គ្មាននរណាម្នាក់អាច « រកបាន » ឬ « សមនឹង » សេចក្ដីសង្គ្រោះនោះទេ ប៉ុន្តែវាជាធម្មតាទេដែលយើងឆ្ងល់ថា តើព្រះអម្ចាស់ទទួលយកយើងឬអត់នោះ ។ . . .

ខ្ញុំសូមនិយាយឲ្យត្រង់ និងច្បាស់លាស់ ។ ចម្លើយចំពោះសំណួរថា « តើខ្ញុំបានគ្រប់លក្ខណ៍ហើយឬនៅ ? » និង « តើខ្ញុំអាចបានគ្រប់លក្ខណ៍ដែរឬទេ ? » គឺថា « មែនហើយអាចបាន ! បងប្អូននឹងបានគ្រប់លក្ខណ៍ » មែនហើយ « បងប្អូននឹងធ្វើវាបាន ដរាបណាបងប្អូនបន្តប្រែចិត្ត ហើយពុំដោះសារ ឬបះបោរនោះ » ។ ព្រះមិនមែនជាអាជ្ញាកណ្ដាលចិត្តអាក្រក់ ដែលសម្លឹងមើលរាល់ការដោះសារដើម្បីដកយើងចេញពីនគរទ្រង់ឡើយ ។ ទ្រង់ជាព្រះវរបិតាដ៏ឥតខ្ចោះ ដែលសព្វព្រះទ័យឲ្យកូនចៅទ្រង់ទាំងអស់ត្រឡប់ទៅស្ថានសួគ៌ ហើយរស់នៅជាមួយទ្រង់ជាគ្រួសារវិញជារៀងរហូត ជាងអ្វីៗទាំងអស់ ។ ទ្រង់ពិតជាបានប្រទានព្រះរាជបុត្រាបង្កើតតែមួយ ដើម្បីឲ្យយើងមិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ ! សូមជឿចុះ ហើយបន្តមានក្តីសង្ឃឹម និងការលួងលោមចិត្តមកពីក្តីពិតដ៏អស់កល្បនេះ ។ ព្រះវរបិតាសួគ៌យើងសព្វព្រះទ័យឲ្យយើងត្រឡប់ទៅឯទ្រង់វិញ ! នោះគឺជាកិច្ចការ និងសិរីល្អរបស់ទ្រង់ ។ ( ជេ ដេវណ៍ ខូនីស្ស « Am I Good Enough? Will I Make It? » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៦ ទំព័រ ៣២–៣៣ )

## តើខ្ញុំអាចធ្វើអ្វីខ្លះ ដើម្បី « បានធ្វើឲ្យល្អឥតខ្ចោះតាមរយៈព្រះយេស៊ូវ » ?

ស៊ីស្ទើរ ខារ៉ុល អេហ្វ ម៉ាកខន់ឃី អតីតគណៈប្រធានយុវនារីទូទៅបានបង្រៀន ៖



សេចក្ដីសង្ឃឹមរបស់យើងដើម្បីបានសេចក្ដីបរិសុទ្ធ គឺផ្ដោតទៅលើព្រះគ្រីស្ទ និងក្ដីមេត្តាករុណា និងព្រះគុណរបស់ទ្រង់ ។ តាមការមានក្ដីជំនឿលើព្រះយេស៊ូវគ្រីស្ទ និងលើដង្វាយធួនរបស់ទ្រង់ នោះយើងអាចបានស្អាតស្អំ គ្មានស្នាមប្រឡាក់ ខណៈដែលយើងមិនបណ្ដោយខ្លួនទៅក្នុងសេចក្ដីអាក្រក់ [ សូមមើល ម៉ូរ៉ូណៃ ១០:៣២–៣៣ ] ហើយប្រែចិត្តដោយស្មោះនោះ ។ យើងបានទទួលបុណ្យជ្រមុជទឹក សម្រាប់ការផ្ដាច់បាប ។ ព្រលឹងយើងត្រូវបានធ្វើឲ្យបរិសុទ្ធ នៅពេលយើងទទួលព្រះវិញ្ញាណបរិសុទ្ធដោយស្មោះសរ ។ រាល់សប្ដាហ៍ យើងទទួលពិធីសាក្រាម៉ង់ ។ ពេលយើងមានស្មារតីប្រែចិត្តដោយមានបំណងដ៏ស្មោះដើម្បីមានភាពសុចរិត នោះយើងចុះសេចក្ដីសញ្ញាថា យើងនឹងមានឆន្ទៈលើកដាក់ព្រះនាមនៃព្រះគ្រីស្ទមកលើខ្លួន ចងចាំទ្រង់ ហើយគោរពតាមព្រះបញ្ញត្តិទាំងឡាយ ដើម្បីយើងអាចមានព្រះវិញ្ញាណរបស់ទ្រង់គង់ជាមួយយើងជានិច្ច ។ យូរៗទៅ ពេលយើងព្យាយាមជាបន្តបន្ទាប់ដើម្បីមានបំណងតែមួយជាមួយព្រះវរបិតា ព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ នោះយើងបានជាអ្នកទទួលបាននិស្ស័យនៃព្រះ [ សូមមើល ពេត្រុស ទី២ ១:៤ ] ។ ( ខារ៉ុល អេហ្វ ម៉ាកខន់ឃី « The Beauty of Holiness » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ១០ )

អែលឌើរ ឌែល ជី រិនឡាន់ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



ព្រះយកព្រះទ័យទុកដាក់ខ្លាំងថាតើយើងជានរណា ហើយយើងនឹងក្លាយជានរណា ច្រើនជាងថាតើកាលពីមុនយើងជានរណា ។ ទ្រង់យកព្រះទ័យទុកដាក់ថា តើយើងបន្តការព្យាយាមដែរឬទេ ។ ( ឌែល ជី រិនឡាន់ « Latter-day Saints Keep on Trying » *Liahona* ខែ ឧសភា ឆ្នាំ ២០១៥ ទំព័រ ៥៦ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ឆ្នាំ ២០២៤ by Intellectual Reserve, Inc. All rights reserved. PD80007812_258_273-1